ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិ សុខភាព
និងសុវត្ថិភាពការងារ
លេខ.....០០៤/..គ.ជ.ស.ក

ថ្ងៃពុធ ៧កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៨

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ ទប់ស្កាត់ករណីដួលសន្លប់ របស់កម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថាន

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

-យោងលិខិតបង្គាប់ការលេខ ០២២សខល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

ប្រការ ១..

ត្រូវបានបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ ទប់ស្កាត់ករណីដួលសន្លប់របស់កម្មករនិយោជិត នៅតាមសហគ្រាស គ្រឹះស្ថានដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តមបណ្ឌិត	**អ៊ុត សំហេង**	រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
២-ឯ.ឧ សាស្ត្រាចារ្យ	**អេង ហួត**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	អនុប្រធាន
៣-ឯកឧត្តមវេជ្ជ.	**ហ៊ុយ ហានសុខ**	រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធានអចិន្ត្រៃយ៍
៤-ឯកឧត្តម	**ផេង សុខាំ**	អនុរដ្ឋលេខាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៥-ល.ជ សាស្ត្រាចារ្យ	**អ៊ុំ សាម៉ុល**	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិកា
៦-ឯកឧត្តម	**សឺម យ៉ារ៉ែន**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៧-ឯកឧត្តម	**កៅ ចារ៉ូ**	អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល	សមាជិក
៨-ឯកឧត្តម	**កៅ ផល**	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ	សមាជិក
៩-ឯកឧត្តម	**ជា ភុទ្ធី**	អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១០-ឯ.ឧ សាស្ត្រាចារ្យ	**ឈួយ ម៉ៅង**	ទីប្រឹក្សាក្រសួងសុខាភិបាល	សមាជិក
១១-ឯកឧត្តម	**ហេង សួរ**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក
១២-ឯកឧត្តម	**សេង សង្កា**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ	សមាជិក
១៣-ឯកឧត្តម	**ឡៅ ហ៊ីម**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានTVET	សមាជិក
១៤-ឯកឧត្តម	**អ៊ុក សមវិទ្យា**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក នាយកបេឡាជាតិរបបសន្តិសុខសង្គម	សមាជិក
១៥-លោកជំទាវវេជ្ជ.	**ឱ វណ្ណឌីន**	អគ្គនាយកបច្ចេកទេសសុខាភិបាល	សមាជិកា
១៦-ឯ.ឧសាស្ត្រាចារ្យ	**សាផុន វឌ្ឍនៈ**	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល	សមាជិក
១៧-លោកជំទាវ	**ជា សុខនី**	ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិកា

		នៃអគ្គនាយកដ្ឋានការងារ	សមាជិកា
១៩-ល.សាស្ត្រាចារ្យ	**រង ឆវណ្ណ**	នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ	សមាជិក
២០-លោកវេជ្ជ.	**ឈិត សុផល**	ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន	សមាជិក
២១-លោក	**សារិ ផល្លា**	ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម	សមាជិក
២២-លោក	**ខេន លូ**	អគ្គលេខាធិការនៃសមាគមកាត់ដេរនៅកម្ពុជា	សមាជិក
២៣-លោក	**គីម ពេជ្ជា**	ប្រធានផ្នែកការងារនិងច្បាប់នៃសមាគមកាត់ដេរនៅកម្ពុជា	សមាជិក
២៤-លោក	**តោ ជារ៉ារិទ្ធ**	មន្ត្រីការងារ នៃសមាគមកាត់ដេរនៅកម្ពុជា	សមាជិក
២៥-លោក	**ជួន ម៉ុំថុល**	ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា	សមាជិក
២៦-លោកស្រី	**ឆេត គីមវណ្ណារី**	អនុប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា	សមាជិកា
២៧-លោក	**ណៃ សុខាសនា**	អគ្គហិរញ្ញិកសហភាពសហព័ន្ធសហជីពជាតិកម្ពុជា	សមាជិក
២៨-លោកស្រី	**ផន សុផារី**	តំណាងអង្គការសុខភាពពិភពលោក	សមាជិកា
២៩-លោក	**ឆុន សុភ័ណ**	អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃអង្គការ ILO	សមាជិក
៣០-លោកស្រី	Esther Germans	ប្រធានគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការ ILO	សមាជិកា

ប្រការ ២..

ក្រុមការងារនេះមានភារកិច្ច៖

- ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយ និងដំណោះស្រាយដើម្បីទប់ស្កាត់ការដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- គ្រប់គ្រង និងសម្របសម្រួលការសិក្សាស្រាវជ្រាវដើម្បីរកវិធីសាស្ត្របង្ការការដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ
- រៀបចំបទប្បញ្ញតិចាំបាច់ដើម្បីបង្ការ និងទប់ស្កាត់ការដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ
- ផ្តល់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ករណីដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- ពិនិត្យ និងផ្តល់យោបល់លើផែនការសកម្មភាពពាក់ព័ន្ធនឹងការទប់ស្កាត់ការដួលសន្លប់និងបង្ការគ្រោះថ្នាក់ការងារ
- ពិនិត្យ និងផ្តល់យោបល់លើកម្មវិធីអប់រំ/ផ្សព្វផ្សាយពីវិធានការទប់ស្កាត់ការដួលសន្លប់ និងការបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- សហការ និងសម្របសម្រួលជាមួយបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងសង្គមស៊ីវិល ដើម្បីគៀរគរធនធាន បច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្រដល់សកម្មភាពលើកកម្ពស់ការទប់ស្កាត់ការដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- ធ្វើរបាយការណ៍ការងារ សេចក្តីព្រាងនៃការសន្និដ្ឋានចុងក្រោយ និងសេចក្តីសម្រេចនានាជាក់ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារប្រគល់ជូន។ HS

ប្រការ ៣.

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នាយកបេឡាជាតិរបបសន្តិសុខសង្គម និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី និងជាប្រធាន
គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

អ៊ុត សំហេង

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ